**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានីភ្នំពេញ**
**រដ្ឋបាលខណ្ឌចំការមន**
លេខ:...៣០៥/១៩......ស.ជ.ណ

ថ្ងៃ ព្រហស្បតិ៍ ៣រោច ខែ..ជេស្ឋ..ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
ចំការមន,ថ្ងៃទី...២០....ខែ..មិថុនា..ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្លាស់ប្តូរទីតាំងទីស្នាក់ការសាលាខណ្ឌចំការមន

រដ្ឋបាលខណ្ឌចំការមន មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន ស្ថាប័នរដ្ឋ និងឯកជនទាំងអស់ឱ្យបានជ្រាបថា៖ ដោយបច្ចុប្បន្នភូមិសាស្ត្រខណ្ឌចំការមនត្រូវបានរាជរដ្ឋាភិបាលចេញអនុក្រឹត្យបំបែកជា ០២ ខណ្ឌគឺ ខណ្ឌចំការមន(មានចំនួន ០៥សង្កាត់គឺ សង្កាត់ទន្លេបាសាក់, ទួលទំពូងទី២, ទួលទំពូងទី១, បឹងត្របែក និងផ្សារដើមថ្កូវ) និងខណ្ឌបឹងកេងកង (មានចំនួន ០៧ សង្កាត់គឺ សង្កាត់បឹងកេងកងទី១, បឹងកេងកងទី២, បឹងកេងកងទី៣, អូឡាំពិក, ទួលស្វាយព្រៃទី១, ទួលស្វាយព្រៃទី២ និងទំនប់ទឹក) ចំពោះទីស្នាក់ការសាលាខណ្ឌចំការមន ដែលស្ថិតនៅផ្ទះលេខ ១៦៨ មហាវិថីម៉ៅសេទុង ភូមិ ០១ សង្កាត់បឹងកេងកងទី៣ ត្រូវបានប្តូរទៅជាទីស្នាក់ការរបស់សាលាខណ្ឌបឹងកេងកងវិញ។

ចំណែកសាលាខណ្ឌចំការមន ត្រូវបានផ្លាស់ប្តូរមកទីស្នាក់ការថ្មីជាបណ្តោះអាសន្ន ដែលស្ថិតនៅ **អគារ Sales Center (ជាប់ស្ពានអ្នកធ្លង់អគ្គីភ័យកោះពេជ្រ)** ក្នុងទីក្រុងកោះពេជ្រ វិថីកោះពេជ្រ ភូមិ ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី **២០ ខែ មិថុនា ឆ្នាំ ២០១៩** នេះតទៅ។

អាស្រ័យហេតុនេះ សូមសាធារណជន ស្ថាប័នរដ្ឋ និងឯកជនមេត្តាជ្រាបជាព័ត៌មាន។

**អភិបាល នៃគណៈអភិបាលខណ្ឌចំការមន**

**ខេង សុថុល**

**ចម្លងជូន**
- រដ្ឋបាលរាជធានីភ្នំពេញ "ដើម្បីគោរពជូនជ្រាប"
- មន្ទីរជំនាញជុំវិញរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខណ្ឌ
- អធិការនគរបាលខណ្ឌ
- ការិយាល័យជំនាញជុំវិញខណ្ឌ
- ការិយាល័យចំណុះខណ្ឌ
- រដ្ឋបាលសង្កាត់ទាំង០៥
- ផ្សារទាំង ០២
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ

រដ្ឋបាលខណ្ឌចំការមន

## ប្លង់បង្ហាញទីតាំង

## ទីស្នាក់ការថ្មីជាបណ្ដោះអាសន្នរបស់សាលាខណ្ឌចំការមន

ស្ថិតនៅអគារ Sales Center (ជាប់ស្ថានីយ៍ពន្លត់អគ្គីភ័យកោះពេជ្រ) ក្នុងទីក្រុងកោះពេជ្រ
វិថីកោះពេជ្រ ភូមិ ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ





**ទីស្នាក់ការថ្មីបណ្ដោះអាសន្ន**
អគារ Sales Center
(ជាប់ស្ថានីយ៍ពន្លត់អគ្គីភ័យកោះពេជ្រ)

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ចំការមន,ថ្ងៃទី.....ខែ.....ឆ្នាំ ២០១៩

**អភិបាល នៃគណៈអភិបាលខណ្ឌចំការមន**

**ជេង សុថុល**